## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សាមគ្គីឃុំមៀន
## រយៈពេល ៣ឆ្នាំ (ឆ្នាំ២០១៩ - ឆ្នាំ២០២២)

ឈ្មោះសហគមន៍នេសាទ ៖ **សាមគ្គីឃុំមៀន**

ភូមិ ៖ កំពង់សំណាញ់ ទួលព្រិច ដំណាក់ពង្រ ទួលពោន ដីក្រហម កោះ ឃ្លោយទី៣ ផ្កាយព្រឹក កំពង់សិរិទ្ធ

ឃុំ ៖ មៀន

ស្រុក ៖ ព្រៃឈរ

ខេត្ត ៖ កំពង់ចាម

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សាមគ្គីឃុំមៀន
# រយៈពេល ៣ឆ្នាំ (ឆ្នាំ២០១៩ - ឆ្នាំ២០២២)

ឈ្មោះសហគមន៍នេសាទ ៖ **សាមគ្គីឃុំមៀន**

ភូមិ ៖ កំពង់សំណាញ់ ទួលព្រិច ដំណាក់ពង្រ ទួលពោន
ដីក្រហម កោះ ឃ្លោយទី៣ ផ្កាយព្រឹក កំពង់សិរិទ្ធ

ឃុំ ៖ មៀន

ស្រុក ៖ ព្រៃឈរ

ខេត្ត ៖ កំពង់ចាម

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ..........១

ខ- មុខរបរ..........១

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង..........២

ខ- ដែននេសាទ..........២

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស..........២

ឃ- ធនធានជលផល..........២

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ..........៣

ខ- ឧបករណ៍នេសាទ..........៣

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ..........៥

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក- ទស្សនៈវិស័យ..........៥

ខ- គោលបំណង..........៥

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ..........៦

គ២- ផែនការកែលំអដែននេសាទ..........៧

គ៣- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស..........៨

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក..........៨

គ៥- ផែនការទប់ស្កាត់បទល្មើសនេសាទ..........៩

គ៦- ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ......១០

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល..........១០

គ៨- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍..........១១

ឃ. ផែនការយុទ្ធសាស្ត្រ..........១២

**- តារាងសង្ខេបផែនការ**..........១៣

**- តារាងកម្មវិធីការងារ**..........១៥

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ**សាមគ្គីឃុំមៀន** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨។

សហគមន៍នេសាទ**សាមគ្គីឃុំមៀន** មានទីតាំងស្ថិតនៅភូមិបឹងកេះ ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ដែលមានសមាជិកសរុបចំនួន៣០៦នាក់ ប្រុស២៣២នាក់ ស្រី៧៤នាក់ ស្មើនឹង៣០៦គ្រួសារ និងមានគណៈកម្មការចំនួន១១នាក់ ស្ត្រីចំនួន០០នាក់។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការ សហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ និងធ្វើផែនទី
- ចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន១៤៣៤៦នាក់ ប្រុស៧៣៦៨នាក់ ស្រី៦៩៧៨នាក់ ក្នុងនោះ មានចំនួន៣៥៣១គ្រួសារ ដែលជាជនជាតិខ្មែរ

-ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមានចំនួន៩៨% ក្រៅពីនេះមានអ្នកកាន់សាសនាកាតូលិក២%

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៩២នាក់ ស្រី៤១នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន១៥៣នាក់ ស្រី១៨នាក់ កម្រិតមធ្យមសិក្សាចំនួន ៤៦នាក់ ស្រី៩នាក់ និងកម្រិតឧត្តមសិក្សាចំនួន១៥នាក់ ស្រីចំនួន៦នាក់

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១៣នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១២០នាក់ ស្រី៤៩នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ២៥នាក់ ស្រី១១នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៦នាក់ ស្រី៤នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៥នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេះរួមមានៈ

-ធ្វើនេសាទចំនួន៨៦ គ្រួសារ

-ធ្វើស្រែចំនួន១៨២ គ្រួសារ ទំហំ១២៧,៤ ហិកតា

-ធ្វើវារីវប្បកម្មចំនួន ១០គ្រួសារ ស្រះចំនួន៥ស្រះ ទំហំ ០,៣៧ហិកតា បែត្រីចំនួន៥

-ដាំបន្លែចំនួន ១២គ្រួសារ ទំហំ០,១២ហិកតា

-ជាងផ្ទះចំនួន ៤គ្រួសារ

-លក់ដូរចំនួន០៣ គ្រួសារ

-កម្មការ៣៥ គ្រួសារ

-ប្រាក់ចំណូលជាមធ្យមក្នុង០១គ្រួសារប្រចាំឆ្នាំមានចំនួន ២.៩២០.០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍**សាមគ្គីឃុំមៀន**ត្រូវលុបចេញពីអតីតឡូត៍នេសាទលេខ២ ដែននេសាទទឹកសាបក្នុងខេត្តកំពង់ចាម មានទំហំ **២៩៣**ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

-ខាងជើងទល់នឹង ៖ ភូមិដំណាក់ពង្រ ឃុំមៀន

-ខាងត្បូងទល់នឹង ៖ បឹងធំ ឃុំរការគយ និងឃុំកំពង់សៀម

-ខាងកើតទល់នឹង ៖ ទំនប់ត្រើង ភូមិត្រើង

-ខាងលិចទល់នឹង ៖ បឹងកេះ ភូមិកេះ និងឃុំព្រែកក្របៅ

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទ**សាមគ្គីឃុំមៀន** មានបឹងចំនួន២បឹងគឺៈ

-បឹងកេះ ទំហំ ៩៤,៦ ហិកតា នេសាទពីពេញមួយឆ្នាំ

-បឹងធំ (មួយផ្នែកនៃបឹងធំ) ទំហំ ៨៦,១ ហិកតា នេសាទពីពេញមួយឆ្នាំ

-ដីទំនាបលិចទឹកមានទំហំសរុប ២៩៣ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

-បឹងកេះ ទំហំ២ ហិកតា (២០០មX១០០ម) ចំណុចកណ្តាលបឹងកេះ

មាននិយាមកាដូចខាងក្រោមៈ

| X | Y | ចំណុចគោលដៅ |
|---|---|---|
| 533564 | 1327535 | ខាងជើងឈៀងខាងលិច |
| 533612 | 1327448 | ខាងលិចឈៀងខាងត្បូង |

| | | |
|---|---|---|
| 533800 | 1327547 | ខាងត្បូងឈៀងខាងកើត |
| 533755 | 1327641 | ខាងកើតឈៀងខាងជើង។ |

**ឃ. ធនធានផលផល**

**-ប្រភេទត្រី ៖**

ត្រីរស់ ត្រីប្រា ត្រីឆ្តោរ ត្រីឆ្លាំង ត្រីកែស ត្រីឆ្ដោក ត្រីក្អែក ត្រីក្រសក់ ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីរាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ក្លាំងហាយ ត្រីខ្មាន់ ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្រ្ចូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីគ្រឹម ត្រីគ្រឹមទន្សាយ ត្រីស្រកាវក្ដាម ត្រីលលកសរ ត្រីឆ្ពិន ត្រីជញ្ជក់ ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្ដាតឆ្កែ កំពិស បង្កង។

**-ប្រភេទវារីសត្វ ៖**

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្ដាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

**-ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖**

ដើមថ្លើមអណ្តើក ខ្លបយក្ស(អូយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លើង អញ្ចាញ ត្នួ កន្សែង ស្នែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្នាង ត្នួ ខ្នាយមាន់ វល្លិប្រេង វល្លិទឹកដោះ វល្លិត្រដិត វល្លិដោះគន់ វល្លិត្រី វល្លិត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហែ ស្មោ ស្លត បន្លាឃ្លេ ថ្ងាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្ដៅ ភ្នែកព្រាប វល្លិអណ្ដាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្ពន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំប្លង កក់ជ្រុង កក់ក្ដាម ឈូក ចន្ទល់ភ្នំ(វល្លិថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ ៖**

-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៨៦នាក់ ស្រី ៧៤នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ៤៧៥នាក់ ស្រី១៧៩នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១០០នាក់ ស្រី១៥ នាក់

## ខ. ឧបករណ៍នេសាទ ៖

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ត្បូង | ៣០៦ | ១.៤០០ម/គ្រួសារ | ៤២៨,៤០០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១០០ | ៥០០ផ្លែ/គ្រួសារ | ៥០,០០០ផ្លែ | ខែកក្កដា ដល់ ខែវិច្ឆិកា |
| លបត្រី | គ្រឿង | ២០ | ២០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ខែកក្កដា ដល់ ខែកុម្ភៈ |
| លបកំពិស | គ្រឿង | ៣០ | ២០០គ្រឿង/គ្រួសារ | ៦,០០០គ្រឿង | ខែកក្កដា ដល់ ខែមេសា |
| សំណាញ់ | វង់ | ៤១ | ២វង់/គ្រួសារ | ៨២វង់ | ពេញមួយឆ្នាំ |
| ទ្រូ | គ្រឿង | ១០ | ២គ្រឿង/គ្រួសារ | ២០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| បបក់ | គ្រឿង | ៦ | ១គ្រឿង/គ្រួសារ | ៦គ្រឿង | ខែធ្នូ ដល់ ខែឧសភា |
| អង្រុត | គ្រឿង | ២៥ | ១គ្រឿង/គ្រួសារ | ២៥គ្រឿង | ខែកក្កដា ដល់ ខែមេសា |
| អួនអូសដៃ | វង់ | ២៥ | ៥០ម/គ្រួសារ | ២៥វង់ | ខែកុម្ភៈ ដល់ ខែឧសភា |
| អួនស្បៃមុង | វង់ | ១៦ | ២៥០ម/គ្រួសារ | ១៦វង់ | ខែកុម្ភៈ ដល់ ខែកក្កដា |
| អួនឆក់ត្រជាក់ | វង់ | ៨ | ១៥ម/គ្រួសារ | ៨វង់ | ខែមករា ដល់ ខែកក្កដា |
| សម្រាស់ | ដុំ | ១០ | ៣ដុំ/គ្រួសារ | ៣០ដុំ | ខែតុលា ដល់ ខែកក្កដា |
| ឆក់ក្ដៅ | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |
| លូស្បៃមុង | គ្រឿង | ២០ | ៣គ្រឿង/គ្រួសារ | ៦០គ្រឿង | ពេញមួយឆ្នាំ |
| លូស្បៃមុង | គ្រឿង | ២០ | ៣គ្រឿង/គ្រួសារ | ៦០គ្រឿង | ពេញមួយឆ្នាំ |
| រ៉ាវ | មាត់ | ៣ | ២មាត់/គ្រួសារ | ៦មាត់ | ខែកក្កដា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦១គ្រឿង | ២០០-៥០០គីឡូក្រាម | ៣-៥សេះ |
| ទូកអុំ និងចែវ | ១៩គ្រឿង | ៥០-១៥០ គីឡូក្រាម | |

-ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ត្បូង | ៤៧៥ | ១,០៥០ម/គ្រួសារ | ៤៩៨,៧៥០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៩៧ | ៥០០ផ្លែ/គ្រួសារ | ៤៨,៥០០ផ្លែ | ខែកក្កដា ដល់ ខែវិច្ឆិកា |
| លបត្រី | គ្រឿង | ៧៦ | ១០គ្រឿង/គ្រួសារ | ៧៦០គ្រឿង | ខែកក្កដា ដល់ ខែកុម្ភៈ |

| | | | | | |
|---|---|---|---|---|---|
| លបកំពីស | គ្រឿង | ៣២ | ១៥០គ្រឿង/គ្រួសារ | ៤,៨០០គ្រឿង | ខែកក្កដា ដល់ ខែមេសា |
| សំណាញ់ | វង់ | ៣៧ | ១វង់/គ្រួសារ | ៣៧វង់ | ពេញមួយឆ្នាំ |
| អួនអូសដៃ | វង់ | ១៥ | ៥០ម/គ្រួសារ | ១៥វង់ | ខែកុម្ភៈ ដល់ ខែឧសភា |
| អួនស្បៃមុង | វង់ | ៨ | ២៥០ម/គ្រួសារ | ៨វង់ | ខែកុម្ភៈ ដល់ ខែកក្កដា |
| អួនឆក់ត្រជាក់ | វង់ | ៨ | ១៥ម/គ្រួសារ | ៨វង់ | ខែមករា ដល់ ខែកក្កដា |
| សម្រាស់ | ដុំ | ៣០ | ២ដុំ/គ្រួសារ | ៦០ដុំ | ខែតុលា ដល់ ខែកក្កដា |
| ឆក់ក្តៅ | គ្រឿង | ៩៣ | ១គ្រឿង/គ្រួសារ | ៩៣គ្រឿង | ពេញមួយឆ្នាំ |
| លូស្បៃមុង | គ្រឿង | ១១៧ | ៣គ្រឿង/គ្រួសារ | ៣៥១គ្រឿង | ពេញមួយឆ្នាំ |
| រ៉าវ | មាត់ | ១៦ | ២មាត់/គ្រួសារ | ៣២មាត់ | ខែកក្កដា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៤០២គ្រឿង | ២០០-៥០០គីឡូក្រាម | ៣-៥សេះ |
| ទូកអុំ និងចែវ | ៥៥គ្រឿង | ៥០-១៥០ គីឡូក្រាម | |

-ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ត្បូង | ២០ | ១,០៥០ម/គ្រួសារ | ២១,០០០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៥ | ៥០០ផ្លែ/គ្រួសារ | ២,៥០០ផ្លែ | ខែកក្កដា ដល់ ខែវិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ១០ | ៥០ផ្លែ/គ្រួសារ | ៥០០ផ្លែ | ខែកក្កដា ដល់ ខែវិច្ឆិកា |
| សំណាញ់ | វង់ | ៥ | ១វង់/គ្រួសារ | ៥វង់ | ពេញមួយឆ្នាំ |
| អួនអូសដៃ | វង់ | ១០ | ៥០ម/គ្រួសារ | ១០វង់ | ខែកុម្ភៈ ដល់ ខែឧសភា |
| ឆក់ | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |
| រ៉ាវ | មាត់ | ៤ | ៣មាត់/គ្រួសារ | ១២មាត់ | ខែកក្កដា ដល់ ខែមេសា |
| លាន់ | គ្រឿង | ១០ | ៥០គ្រឿង/គ្រួសារ | ៥០០គ្រឿង | ខែកុម្ភៈ ដល់ ខែកក្កដា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | 0 | 0 | 0 |
| | | | |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី ចំរុះ | ៣៤៦គីឡូក្រាម | ២៩៣គីឡូក្រាម | ៦៣៩គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទ**សាមគ្គីឃុំមៀន**មានទស្សនៈវិស័យចូលរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ

កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវតំឡើង នាទីព្រៃលិចទឹក

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាពនិងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| | ខែតុលា-ឧសភា | មង | ១៥០ម/គ្រួសារ | ៨៦គ្រួសារ | សមាជិកសហគមន៍ |

| | | | | | |
|---|---|---|---|---|---|
| | | | | | ខាងក្នុង និងខាងក្រៅ |
| | ខែកក្កដា - ខែវិច្ឆិកា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| បឹងកេះ | ពេញមួយឆ្នាំ | សន្ទូចបង្កៃ | ៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១គ្រឿង/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | ទ្រូ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | ឈ្នាងជញ្ជាត់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | រាវលៀស | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | ថ្នងដងកំពិស | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ខែធ្នូ - ខែឧសភា | បបក់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | អង្រុត | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ខែតុលា - ឧសភា | មង | ១៥០ម/គ្រួសារ | ៨៦គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ខែកក្កដា ដល់ ខែវិច្ឆិកា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | សន្ទូចបង្កៃ | ៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ខែមិថុនា - ខែកុម្ភៈ | លបត្រី | ៧គ្រឿង/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| ចំណុចបឹងធំ | ពេញមួយឆ្នាំ | លបកំពិស | ៥០គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១គ្រឿង/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | ទ្រូ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | មិថុនា - សីហា | លាន់ | ៥០គ្រឿង/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | ឈ្នាងជញ្ជាត់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |

| | | | | | |
|---|---|---|---|---|---|
| | ពេញមួយឆ្នាំ | រាវលៀស | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | ថ្មង់កំពិស | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ខែធ្នូ - ឧសភា | បបក់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |
| | ពេញមួយឆ្នាំ | អង្រុត | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ ខាងក្នុង និងខាងក្រៅ |

**គ.២ ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម - បញ្ចប់ |
|---|---|---|---|---|---|
| បឹងកេះ | ៩៤,៦ ហិកតា | ៥ ហិកតា ៥០.០០០ម$^{៣}$ | គ្រឿងចក្រស្តារឡើងវិញ ឬ ម៉ាស៊ីនបូមដី | ៥០,០០០ | ២០១៩ - ២០២១ |
| | | | ស្វែងរកម្ចាស់ជំនួយ | ៣០០ | ២០១៩ - ២០២០ |
| | | | ប្រជុំផ្សព្វផ្សាយ | ៥០០ | ២០១៩ - ២០២១ |
| ចំណុចទួលក្រហមកទៅទួលក្រគៀបក្តាម | ៤៥២ ម | ៣៥៦ម x(៤ម-៧ម)x៣ម (៥.៨៧៤ម$^{៣}$) | គ្រឿងចក្រលើកទំនប់ | ៧៣,៤២ ៥ | ២០១៩ - ២០២១ |
| | | | ស្វែងរកម្ចាស់ជំនួយ | ៣០០ | ២០១៩ - ២០២១ |
| | | | ប្រជុំផ្សព្វផ្សាយ | ៥០០ | ២០១៩ - ២០២១ |
| | | ២០ម | ទំនប់បង្ហៀរ | ៥,៨០០ | ២០១៩ - ២០២១ |

**គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងកេះ | ២ ហិកតា | ត្រីមេពូជ ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ២ដង/ឆ្នាំ | ៣០០ | ២០១៩ | ២០២១ |
| | | | បោះបង្គោលព្រំតំបន់អភិរក្ស | ១,៥០០ | មេសា២០១៩ | ឧសភា២០២១ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ចំនួន៨បង្គោល | | | |
| | | | ដាក់ស្លាកសញ្ញាចំនួន១ | ១០០ | ឧសភា/២០២០ | |
| | | | ល្បាតការពារជាប្រចាំកន្លែងអភិរក្ស(២ដង/ខែ) | ១,៦២០ | កក្កដា២០១៩ | កក្កដា ២០២១ |
| | | | លែងកូនត្រីពោ, ប្រា, រ៉ស់ និង អណ្តែង ៣០.០០០កូនក្នុង១ឆ្នាំ | ១,៥៣៨ | កក្កដា២០១៩ | កក្កដា២០២១ |
| | | | ចងទ្រនំកំប្លោក រៀងរាល់ឆ្នាំ | ៦០០ | ២០១៩ | ២០២១ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងកេះ | ១៦,៧ ហិកតា | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ៦០០ | មិនា /២០២០ | មិនា /២០២២ |
| | | | ដាំព្រៃលិចទឹក ចំនួន២.០០០ដើម (រាំង, ត្រស់ និង សណ្តាន់) | ៤,០០០ | មិនា/២០២០ | ឧសភា/២០២២ |
| | | | ថែរក្សា ការពារ | ១,២០០ | រយៈពេល៣ឆ្នាំ | |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន ៨ បង្គោល | ១,២០០ | កុម្ភៈ/២០២០ | មេសា/២០២០ |
| | | | ដាក់ស្លាកសញ្ញា ២ | ២០០ | មេសា២០២០ | មេសា២០២០ |

### គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១,២០០ | គណៈកម្មការសមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញ | មិនា និងមិថុនា/រៀងរាល់ឆ្នាំ (បន្ត) | |

| | | | | |
|---|---|---|---|---|
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំឆមាស | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្ត ការងារ | ១២០<br>(២ដង/ឆ្នាំ) | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ | មករា និងមិថុនា/រៀងរាល់ឆ្នាំ(៣ឆ្នាំ) |
| អនុវត្តផែនការៈ (រៀបចំកំលាំងចុះបង្ក្រាបដល់ទី ، កន្លែងដោយទំនាក់ទំនង និង សហការជាមួយអាជ្ញាធរមូល ដ្ឋាន និងអង្គភាពពាក់ព័ន្ធ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៣,៦០០<br>(៥០/ដង) | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | (២ដង/ខែ) ជាប្រចាំ (រយៈពេលបីឆ្នាំ) |

### គ៦-ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តបន្ត | ៣៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ១៥/រៀងរាល់ខែ រយៈពេល(៣ឆ្នាំ) | |
| ទិញសម្ភារៈការិយាល័យ | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៩០ | គណៈកម្មការ | រយៈពេល(៣ឆ្នាំ) | |

### គ៧-ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ និងបទពិសោធន៍ដែលទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាច | ៦៤៥ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូរ | មេសា/រៀងរាល់ឆ្នាំ (៣ឆ្នាំ) | |
| បិទផ្សាយឯកសារសហគមន៍១ដង/ឆ្នាំ | | ៣០ | | ខែមករា/ (រាល់ឆ្នាំ) | ខែមករា (រាល់ឆ្នាំ) |

| | | | | | |
|---|---|---|---|---|---|
| ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ | រកត្រីបានច្រើននាំឲ្យជីវភាពធូរធារ | ៣០០ | | មិថុនា (រាល់ឆ្នាំ) | មិថុនា (រាល់ឆ្នាំ) |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-ភាពជាអ្នកដឹកនាំស.ន<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកា និងគ្រប់គ្រងថវិកា | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ១,៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | (ម្តង /ឆ្នាំ) មករា (រាល់ឆ្នាំ) | មករា (រាល់ឆ្នាំ) |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ (៣នាក់) | ៣១៥ | គណៈសហគមន៍នេសាទ | ឧសភា-ធ្នូ/២០២០ | |

## គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | តុលា/២០១៩ (រៀងរាល់ឆ្នាំ) | ខែធ្នូ /២០១៩ | ៣៨.២៥ | ៥០០រៀល/នាក់ (៣០៦នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំអ្នកនេសាទជាប្រចាំ ២.០០០០ រៀល/ម្នាក់ អ្នកនេសាទម្តងម្កាល ៥.០០០រៀល/នាក់ និងអ្នកមិននេសាទ១.០០០ រៀល/នាក់ | ខែមករា /២០២០ | ខែធ្នូ /២០២០ | ៦៦៧ | -ប្រចាំ៨៦នាក់ ២០,០០០ រៀល/នាក់<br>-ម្តងម្កាល១៨២ នាក់ ៥,០០០ រៀល/នាក់<br>-មិននេសាទ៣៨ នាក់ ១, ០០០ រៀល/នាក់<br>(រយៈពេល៣ឆ្នាំ) |
| ប្រាក់ចំណូលពីអ្នកនេសាទមិនមែនជា | -ផ្សព្វផ្សាយជូនដំណឹង<br>-ដល់សមាជិកក្រៅស.ន | ជាប្រចាំ | | ១,៧១៥ | ១៥.០០០រៀល/ទូក (ជិះពីទូកក[illegible]ឆ្នាំ) |

| | | | | | |
|---|---|---|---|---|---|
| សមាជិកបង់កម្រៃការធ្វើនេសាទ | បង់ប្រាក់កម្រៃធ្វើនេសាទ<br>-ធ្វើកិច្ចសន្យានិងប្រមូលកម្រៃនេសាទ | | | | (រយៈពេល ៣ឆ្នាំ) |
| សរសេរគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាល សប្បុរសជន និងអង្គការដៃគូពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដានដាក់បញ្ចូលផែនការប្រជុំជាមួយឃុំ | ២០១៩ | ២០២២ | ១៥១,៨៤៣ | |
| **សរុប** | | | | **១៥១,៨៤៣** | ដោយមិនបានបូកបញ្ចូលចំណូលពីសមាជិកភាគទានរឺការបង់កម្រៃរបស់អ្នកនេសាទ |

## ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញអង្គការនានាគម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយដាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្ត ផែនការគ្រប់គ្រងនេះ

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
-រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
-ពង្រឹងសមត្ថិភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្ត ផែនការ
-បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ
-រៀបចំធ្វើស្លាក់ការសហគមន៍នេសាទចំនួនមួយខ្នង និងទិញទូកម៉ាស៊ីនចំនួន ១គ្រឿង សម្រាប់គ្រប់គ្រង និងថែរក្សា ការពារកន្លែងនេសាទសហគមន៍ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សាមគ្គីឃុំមៀន រយៈពេល ៣ ឆ្នាំ (ខែកក្កដា ឆ្នាំ២០១៩ ដល់ ខែមិថុនា ឆ្នាំ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ ឧបករណ៍នេសាទ | ធ្វើនេសាទ | -ត្រីកើន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិង គណៈកម្មការ | ២០១៩ | ២០២២ |
| ២.ការកែលំអកន្លែង នេសាទសហគមន៍ | -ប្រើគ្រឿងចក្រស្តារ<br>-ស្វែងរកម្ចាស់ជំនួយ<br>-ប្រជុំផ្សព្វផ្សាយ<br>-សាងសង់ទំនប់បង្ហារ | ត្រីកើន | ១៣០,៨២៥ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការ និងសប្បុរសជន | ២០១៩ | ២០២២ |
| ៣.ការកំណត់ និង រៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយ<br>-បោះបង្គោល និងដាក់ស្លាកសញ្ញា<br>-ការពារ<br>-លែងកូនត្រី និងចងទ្រនំកំប្លោក | ត្រីកើនឡើងវិញ | ៥,៦៥៨ | -ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ |
| ៤.ផែនការគ្រប់គ្រង ព្រៃលិចទឹក | -ផ្សព្វផ្សាយ<br>-ដាំព្រៃលិចទឹក និងការពារ<br>-បោះបង្គោល និងដាក់ស្លាកសញ្ញា | -ព្រៃលិចទឹកកើន<br>-ត្រីកើន | ៧,២០០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការ និងសប្បុរសជន | ២០១៩ | ២០២១ |
| ៥.ផែនការទប់ស្កាត់ បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-ចុះអនុវត្តផែនការ | -ធនធានព្រៃលិចទឹក និងជលផលកើនឡើង<br>-ប្រជាពលរដ្ឋមានជីវភាពធូរធារ | ៤,៩២០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការ និងសប្បុរសជន | ២០១៩ | ២០២២ |
| ៦. ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការស.ន | -ប្រជុំ<br>-ទិញសម្ភារៈការិ យាល័យ | -របាយការណ៍លទ្ធ ផលសម្រេចបានប្រចាំខែ<br>-មានសម្ភារៈការិ យាល័យ | ៤៥០ | ស.ន.ស.គ.ឃ.ម | ២០១៩ | ២០២២ |
| ៧. ផែនការផ្សព្វផ្សាយ និង បណ្តុះបណ្តាល | -ផ្សព្វផ្សាយ<br>-បិទផ្សាយឯកសារ<br>-ចែកឯកសារ | គណៈកម្មការនិងសមាជិក សហគមន៍នេសាទ និង ប្រជាពលរដ្ឋមានការយល់ដឹង | ២,៧៩០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការ និងសប្បុរសជន | ២០១៩ | ២០២២ |
| ៨.[illegible]ទ្រទ្រង់ [illegible]នេសាទ | -ប្រមូលភាគទាន សមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ | មានថវិកាអនុវត្តសកម្មភាព | | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល | ២០១៩ | ២០២២ |

## តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ ខែកក្កដា ២០១៩ ដល់ ខែមិថុនា២០២២

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | ២០២០ | | | | | ២០២១ | | | | | ២០២២ | | | | | |
| | កក្កដា | សីហា | កញ្ញា | ... | ធ្នូ | មករា | កុម្ភៈ | មីនា | ... | ធ្នូ | មករា | កុម្ភៈ | មីនា | .... | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអកន្លែងនេសាទសហគមន៍ | | | | | | x | x | x | | | | x | x | x | x | x | x | x | | | |
| ៣.ការកំណត់ និងរៀបចំកន្លែងអភិរក្ស | x | | | | | | x | x | x | x | | | x | x | | | x | x | x | x | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | x | x | x | x | | x | x | x | x | x | x | x | x | x | x | x |
| ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | x | | x | | x | | x | | x | x | x | x | x | x | x | | | |
| ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈការិយាល័យ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៨.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |